

# យុទ្ធសាស្ត្រ

# ស្តីពី

# ការផ្សព្វផ្សាយព័ត៌មានក្រុមប្រឹក្សាក្រុងបាត់ដំបង

មីនា ២០១៤

# មាតិកា


**១. សេចក្តីផ្តើម**......3

**២ យុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មាន**......3

២.១ ក្រុមផ្សព្វផ្សាយព័ត៌មាន......4

២.១.១ សមាសភាពក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង......4

២.១.២ ភារកិច្ចរបស់ប្រធានក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង......4

២.១.៣ ភារកិច្ចរបស់សមាជិកក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង......4

២.១.៤ មធ្យោបាយផ្សព្វផ្សាយ និងប្រភេទព័ត៌មាន......5

២.១.៥ ប្រភេទព័ត៌មានជាអាទិភាពត្រូវផ្សព្វផ្សាយ......5

២.២ អនុស្សារណៈយោគយល់គ្នា ជាមួយមន្ទីរព័ត៌មានខេត្តបាត់ដំបង ស្តីពីការផ្សព្វផ្សាយព័ត៌មាន......6

**៣. សេចក្តីសន្និដ្ឋាន**......6

**ឧបសម្ព័ន្ធ**......7

ឧបសម្ព័ន្ធ "ក"៖ តារាងយុទ្ធសាស្ត្រសង្ខេបស្តីពីការផ្សព្វផ្សាយព័ត៌មានរបស់ក្រុងបាត់ដំបង......7

ឧបសម្ព័ន្ធ "ខ"៖ សេចក្តីរៀបរាប់លំអិតអំពីមាត្រានានានៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពីការផ្សព្វផ្សាយព័ត៌មាន......14

ឧបសម្ព័ន្ធ "គ"៖ សេចក្តីសម្រេច និងលក្ខខណ្ឌការងាររបស់ក្រុមការងារផ្សព្វផ្សាយព័ត៌មាន......15

# ១. សេចក្តីផ្តើម

នៅក្នុងឆ្នាំ២០១០ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានតាក់តែងឡើង ជារបៀបវារៈការងាររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណើរការកំណែទម្រង់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យដ៏ទូលំទូលាយ និងស៊ីជម្រៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិគឺជាសេចក្តីណែនាំ ដើម្បីជំរុញឱ្យការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិកាន់តែប្រសើរ និងចូលរួមកាត់បន្ថយដល់ភាពក្រីក្រ។ លើកកម្ពស់សិទ្ធិទទួលព័ត៌មាន ក៏បានរំលេចនៅក្នុងកម្មវិធីជាតិ សំដៅសម្របសម្រួលឱ្យប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ក្នុងការទទួលព័ត៌មានពីការសម្រេចចិត្ត និងការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។

ក្នុងន័យបង្ហាញអំពីអភិបាលកិច្ច និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ជាពិសេស ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋពីសិទ្ធិនិងតួនាទីរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ តាមរយៈការទទួលបានព័ត៌មាន ក្រុមប្រឹក្សាក្រុងបាត់ដំបង បានមើលឃើញនូវភាពចាំបាច់ ហើយក៏បានរៀបចំនូវយុទ្ធសាស្ត្រស្តីពី ការផ្សព្វផ្សាយព័ត៌មាននេះឡើង ដើម្បីលើកកម្ពស់ការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយ**អំពីការសម្រេចចិត្ត សកម្មភាព និងសមិទ្ធិផលនានានៃការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាស្របតាមច្បាប់** ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានជាអាទិ៍៖ មាត្រា៣៦ មាត្រា៤១ មាត្រា៥១ មាត្រា៥២ មាត្រា៧៦ មាត្រា១៦៥ និង មាត្រា១៧០។ យុទ្ធសាស្ត្រស្តីពីការផ្សព្វផ្សាយព័ត៌មាននេះ រៀបចំឡើង ដោយផ្អែកទៅតាមយន្តការផ្សព្វផ្សាយព័ត៌មានជាក់ស្តែង ដែលក្រុមប្រឹក្សាក្រុងបាត់ដំបងបានអនុវត្តកន្លងមកនា ឆ្នាំ ២០១៣ ដោយមានការជួយឧបត្ថម្ភពីអង្គការដៃគូនានាធ្វើការនៅក្នុងក្រុងបាត់ដំបង ជាពិសេស "គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"ដែលគាំទ្របច្ចេកទេសដោយអង្គការផេកនៅកម្ពុជា។

# ២ យុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មាន

យុទ្ធសាស្ត្រស្តីពីការផ្សព្វផ្សាយព័ត៌មានរៀបចំឡើង ក្នុងគោលបំណង៖

១) លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពី៖ សកម្មភាពអភិវឌ្ឍន៍នៅក្នុងដែនសមត្ថកិច្ច **សមិទ្ធិផលនៃការបំពេញភារកិច្ច និងការសម្រេចចិត្តនានារបស់**ក្រុមប្រឹក្សាក្រុងបាត់ដំបង។

២) បង្ហាញពីបទពិសោធន៍ជោគជ័យក្នុងការលើកកម្ពស់ការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយសារមានយុទ្ធសាស្ត្រស្តីពីការផ្សព្វផ្សាយព័ត៌មាន។

យន្តការជាយុទ្ធសាស្ត្រ សំខាន់ចំនួនពីរ ដែលក្រុមប្រឹក្សាក្រុងបាត់ដំបងបានប្រើប្រាស់ រួមមាន៖

១. សេចក្តីសម្រេចស្តីពីការបង្កើតក្រុមផ្សព្វផ្សាយព័ត៌មាន និងការអនុវត្តការងារផ្សព្វផ្សាយ។

២. អនុស្សារណៈយោគយល់គ្នារវាងក្រុមប្រឹក្សាក្រុងបាត់ដំបងជាមួយ មន្ទីរព័ត៌មានខេត្តបាត់ដំបង ស្តីពីកិច្ចសហការផ្សព្វផ្សាយព័ត៌មាន។



## ២.១ ក្រុមផ្សព្វផ្សាយព័ត៌មាន

ក្រុមផ្សព្វផ្សាយព័ត៌មានគឺជាយន្តការមួយ ដែលមានរចនាសម្ព័ន្ធច្បាស់លាស់បញ្ជាក់អំពី៖ សមាសភាព មធ្យោបាយ និងប្រភេទព័ត៌មានដែលត្រូវផ្សព្វផ្សាយ។

### ២.១.១ សមាសភាពក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង

ដើម្បីធានាឱ្យការផ្សព្វផ្សាយព័ត៌មានបានដល់ប្រជាពលរដ្ឋ និងងាយស្រួលដល់ការគ្រប់គ្រង សមាសភាពសំខាន់ៗនៃក្រុមផ្សព្វផ្សាយព័ត៌មាន សម្រេចឱ្យមានការចូលរួមពី៖

| | |
|---|---|
| ▪ សមាជិកក្រុមប្រឹក្សាក្រុង ១រូប | ជាប្រធាន |
| ▪ សមាជិកក្រុមប្រឹក្សាក្រុង ២រូបផ្សេងទៀត | ជាសមាជិក |
| ▪ អភិបាលរងក្រុង ១រូប | ជាអនុប្រធាន |
| ▪ នាយករដ្ឋបាលសាលាក្រុង ១រូប | ជាសមាជិកអចិន្ត្រៃយ៍ |
| ▪ ប្រធានការិយាល័យប្រជាពលរដ្ឋ ១រូប | ជាសមាជិក |
| ▪ តំណាងក្រុមប្រឹក្សាសង្កាត់ ១រូប | ជាសមាជិក |
| ▪ តំណាងមន្ទីរព័ត៌មានខេត្ត ១រូប | ជាសមាជិក |
| ▪ តំណាង (ប្រធាន) បណ្តាញសហគមន៍មូលដ្ឋាន ១រូប | ជាសមាជិក |
| ▪ មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ១រូប | ជាលេខាធិការ |

### ២.១.២ ភារកិច្ចរបស់ប្រធានក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង

ភារកិច្ចសំខាន់ៗរបស់ប្រធានក្រុមផ្សព្វផ្សាយព័ត៌មាន រួមមាន៖

- កសាងផែនការសកម្មភាពនៃការផ្សព្វផ្សាយព័តមានឱ្យបានទៀងទាត់ ត្រឹមត្រូវ និងច្បាស់លាស់
- ដឹកនាំ និងគ្រប់គ្រងក្រុមផ្សព្វផ្សាយព័ត៌មាន
- ផ្តល់ព័ត៌មានទាំងឡាយដែលកំណត់ដោយក្របខណ្ឌការងារដល់សមាជិក ដើម្បីឱ្យជួយផ្សព្វផ្សាយបន្តទៅដល់ប្រជាពលរដ្ឋ
- រាយការណ៍អំពីស្ថានភាពនៃការផ្សព្វផ្សាយជូនក្រុមប្រឹក្សាក្នុងរាល់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង
- រៀបចំកិច្ចសន្ទនាជាមួយអ្នកផ្តល់សេវាផ្សព្វផ្សាយព័ត៌មាន
- រៀបចំគម្រោងថវិកាសម្រាប់គាំទ្រដល់ការចំណាយផ្សេងៗ មានការថតចម្លងឯកសារ ការបោះពុម្ពសម្ភារសម្រាប់យកទៅផ្សព្វផ្សាយ និងអប់រំដល់ប្រជាពលរដ្ឋ
- រៀបចំប្រជុំក្រុមផ្សព្វផ្សាយព័ត៌មានឱ្យបានទៀងទាត់ ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃការផ្សព្វផ្សាយ និងធ្វើការបូកសរុបលទ្ធផលនៃការផ្សព្វផ្សាយ ដើម្បីរាយការណ៍ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង។

### ២.១.៣ ភារកិច្ចរបស់សមាជិកក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង

ភារកិច្ចសំខាន់ៗរបស់សមាជិកក្រុមផ្សព្វផ្សាយព័ត៌មាន រួមមាន៖

- នាំព័ត៌មានពីក្រុមប្រឹក្សាក្រុង និងពីប្រធានក្រុម យកទៅផ្សព្វផ្សាយជូនប្រជាពលរដ្ឋឱ្យបានទៀងទាត់
- ផ្តល់យោបល់ត្រលប់ និងរាយការណ៍អំពីមតិយោបល់របស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្សព្វផ្សាយព័ត៌មាន
- ចូលរួមក្នុងកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុម

### ២.១.៤ មធ្យោបាយផ្សព្វផ្សាយ និងប្រភេទព័ត៌មាន

មធ្យោបាយសំខាន់ៗ ដែលក្រុមប្រឹក្សាប្រើប្រាស់ជាយុទ្ធសាស្ត្រ ដើម្បីធានាថាការផ្សព្វផ្សាយព័ត៌មានបានដល់ប្រជាពលរដ្ឋ រួមមាន៖

១) ការចុះពិគ្រោះយោបល់នៅមូលដ្ឋាន

២) វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

៣) កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា

៤) ឧឃោសនស័ព្ទ (មេក្រូ)

៥) ក្តារព័ត៌មាន

៦) តំណាងក្រុមប្រឹក្សាសង្កាត់

៧) បណ្តាញសហគមន៍មូលដ្ឋាន

៨) តាមរយៈមន្ត្រីរដ្ឋបាលផ្ទាល់

### ២.១.៥ ប្រភេទព័ត៌មានជាអាទិភាពត្រូវផ្សព្វផ្សាយ

ប្រភេទព័ត៌មាន ជាយុទ្ធសាស្ត្រដែលក្រុមប្រឹក្សាក្រុងបាត់ដំបងបានផ្សព្វផ្សាយ រួមមាន៖

- ✓ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាក្រុងបាត់ដំបង
- ✓ របៀបវារៈ និងប្រតិទិននៃ៖ កិច្ចប្រជុំប្រចាំខែ ការចុះពិគ្រោះយោបល់នៅមូលដ្ឋាន វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុងបាត់ដំបង
- ✓ លទ្ធផលសង្ខេបនៃកិច្ចប្រជុំប្រចាំខែ ជាពិសេសការពិភាក្សាពីការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ ការសម្រេចចិត្តនានារបស់ក្រុមប្រឹក្សាដែលមានឥទ្ធិពល ឬផលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ
- ✓ គម្រោងអភិវឌ្ឍន៍សង្គមនានាក្នុងមូលដ្ឋានដូចជា ៖ គាំពារសុខភាពមាតានិងទារក អាហាររូបត្ថម្ភ ការអប់រំ សេវាសុខភាព អនាម័យខ្លួនប្រាណនិងការប្រើប្រាស់បង្គន់អនាម័យ ការទទួលបានទឹកសុវត្ថិភាព ការចុះបញ្ជីអត្រានុកូលដ្ឋាន និងសន្តិសុខសុវត្ថិភាព
- ✓ គម្រោងអភិវឌ្ឍន៍ក្នុងមូលដ្ឋានដូចជា ៖ ការស្ថាបនា ស្ពាន ថ្នល់ ទំនប់ ប្រឡាយ ប្រព័ន្ធលូ ធារាសាស្ត្រ សម្បទានដីធ្លី សួនច្បារ បរិស្ថាន បំភ្លឺសាធារណៈ សោភ័ណភាព សណ្តាប់ធ្នាប់
- ✓ ប្រកាសជូនដំណឹងគម្រោងអភិវឌ្ឍន៍ដែលបានអនុម័ត និងសម្រេចដាក់ចូលក្នុងកម្មវិធីវិនិយោគក្រុង
- ✓ គម្រោងផែនការថវិកាចំណូល ចំណាយរបស់ក្រុមប្រឹក្សាក្រុង
- ✓ អត្រាតម្លៃសេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ ដែលបានកំណត់ដោយអន្តរក្រសួង
- ✓ ព័ត៌មានទាក់ទងនឹងផលប្រយោជន៍ និងតម្រូវការរបស់ក្រុមជនងាយរងគ្រោះ ស្ត្រី យុវជន
- ✓ ចំណាត់ការ និងដំណោះស្រាយ ឆ្លើយតបទៅនឹងបញ្ហាដែលប្រជាពលរដ្ឋបានលើកឡើង ។

## ២.២ អនុស្សារណៈយោគយល់គ្នា ជាមួយមន្ទីរព័ត៌មានខេត្តបាត់ដំបង ស្តីពីការផ្សព្វផ្សាយព័ត៌មាន

ក្រៅពីក្រុមការងារផ្សព្វផ្សាយព័ត៌មាន ក្រុមប្រឹក្សាក្រុងបាត់ដំបង យល់ឃើញថា ប្រព័ន្ធផ្សព្វផ្សាយ គឺជាយុទ្ធសាស្ត្រដ៏សំខាន់ ជួយជំរុញការផ្សព្វផ្សាយព័ត៌មានជាសាធារណៈឱ្យបានទូលំទូលាយ ដល់ប្រជាពលរដ្ឋទូទាំងប្រទេស ដោយហេតុដូច្នេះហើយទើបក្រុមប្រឹក្សាក្រុងបាត់ដំបងបានចុះអនុស្សារណៈយោគយល់គ្នា ស្តីពីកិច្ចសហការផ្សព្វផ្សាយព័ត៌មានជាមួយមន្ទីរព័ត៌មានខេត្តបាត់ដំបង ដើម្បីពង្រីកវិសាលភាព និងធានាថា ប្រជាពលរដ្ឋ ជាពិសេសក្នុងក្រុងបាត់ដំបងទទួលបានព័ត៌មានជាក់លាក់ និងទាន់ពេលវេលា ។

## ៣. សេចក្តីសន្និដ្ឋាន

ក្រុមប្រឹក្សាក្រុងបាត់ដំបង សម្រេចបង្កើតយុទ្ធសាស្ត្រស្តីពី ការផ្សព្វផ្សាយព័ត៌មាននេះឡើង ដើម្បីប្រើប្រាស់ជាយន្តការ និងជាមធ្យោបាយ ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ សម្រាប់ចែករំលែកដំណឹង ព្រឹត្តិការណ៍ ហេតុការណ៍ពិតសំខាន់ និងទាន់ពេលវេលា អំពីសកម្មភាពនៃការបំពេញការងារ សមិទ្ធិផល និងការសម្រេចដែលមានការប្រែប្រួលដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ។

យុទ្ធសាស្ត្រស្តីពីការផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបងនេះ ត្រូវបានអនុម័តដោយយោងតាមស្មារតីអង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សានាថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៤ ។

បាត់ដំបង.ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៤

**ប្រធានក្រុមប្រឹក្សាក្រុង**

**ទីម៉ែង-ហាន់**

## ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ "ក"÷ តារាងយុទ្ធសាស្ត្រសង្ខេបស្តីពីការផ្សព្វផ្សាយព័ត៌មានរបស់ក្រុងបាត់ដំបង

| **មធ្យោបាយជាយុទ្ធសាស្ត្រ** | **សកម្មភាពអនុវត្ត** | **ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ** |
|---|---|---|
| **១) ពិគ្រោះយោបល់នៅមូលដ្ឋាន** | កិច្ចពិគ្រោះយោបល់នៅមូលដ្ឋានរបស់ក្រុមប្រឹក្សាសង្កាត់ គឺជាមធ្យោបាយមួយផ្តល់ឱកាសឱ្យក្រុមប្រឹក្សាក្រុងអាចធ្វើការផ្សព្វផ្សាយព័ត៌មានបានក្នុងពេលចុះសង្កេតការណ៍ ដូច្នេះ ដើម្បីប្រាកដថាព័ត៌មានផ្សព្វផ្សាយមានផលប្រយោជន៍ លើកទឹកចិត្តដល់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាក្រុងគិតអំពី ៖<br>**មុនពេលចុះសង្កេតការណ៍ ការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់៖**<br>• កំណត់ និងអនុម័តប្រភេទព័ត៌មានដែលក្រុមប្រឹក្សាក្រុងត្រូវយកទៅផ្សព្វផ្សាយនៅពេលក្រុមប្រឹក្សាសង្កាត់ចុះពិគ្រោះយោបល់នៅមូលដ្ឋាន<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មាន រៀបចំផលិតព័ត៌មានសង្ខេបទៅតាមការអនុម័តរបស់ក្រុមប្រឹក្សា សម្រាប់យកទៅផ្សព្វផ្សាយនៅពេលចុះសង្កេតការណ៍ ការពិគ្រោះយោបល់នៅមូលដ្ឋាន<br>• ស្នើសុំក្រុមប្រឹក្សាសង្កាត់គោលដៅទុកពេលវេលាក្នុងរបៀបវារៈសម្រាប់ចែករំលែកព័ត៌មាន តាមការអនុម័តដោយក្រុមប្រឹក្សាក្រុង<br>**អំឡុងពេលចុះសង្កេតការណ៍ ការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់៖**<br>• ផ្សព្វផ្សាយព័ត៌មាន តាមការរៀបចំដោយក្រុមផ្សព្វផ្សាយព័ត៌មាន<br>• កត់ត្រាបញ្ហាប្រជាពលរដ្ឋលើកឡើងក្នុងពេលសង្កេតការណ៍<br>**ក្រោយពេលចុះសង្កេតការណ៍ ការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់៖** | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្តានុពលដែលក្រុមប្រឹក្សានឹងយកទៅផ្សព្វផ្សាយក្នុងពេលចុះសង្កេត៖<br>• បញ្ហា និងសេចក្តីត្រូវការបានដាក់ក្នុងកម្មវិធីវិនិយោគក្រុង (DIP) ឆ្នាំមុន<br>• ថវិកាចំណាយសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំមុន<br>• ថវិកាចំណាយសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំបច្ចុប្បន្ន<br>• បញ្ហា ក្តីកង្វល់ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាក្រុងបានដោះស្រាយកន្លងមក<br>• ការបិទផ្សាយព័ត៌មានលើក្តារព័ត៌មាន |

| **មធ្យោបាយជាយុទ្ធសាស្ត្រ** | **សកម្មភាពអនុវត្ត** | **ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ** |
|---|---|---|
| | • រៀបចំរបាយការណ៍ និងរាយការណ៍ជូនក្រុមប្រឹក្សាក្រុងក្នុងកិច្ចប្រជុំប្រចាំខែ | |
| **២) វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់** | ដើម្បីធានាថាប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានចូលរួមក្នុងវេទិកា ទទួលបានព័ត៌មានដែលមានប្រយោជន៍ និងលើកកម្ពស់ភាពអង់អាច និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាក្រុង គិតអំពី៖<br>**មុនពេលរៀបចំវេទិកា ៖**<br>• កំណត់ និងអនុម័តប្រភេទព័ត៌មានសម្រាប់យកទៅផ្សព្វផ្សាយក្នុងវេទិកា<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មាន រៀបចំផលិតព័ត៌មានសង្ខេបទៅតាមការអនុម័តរបស់ក្រុមប្រឹក្សាសម្រាប់យកទៅផ្សព្វផ្សាយនៅក្នុងវេទិកា<br>**អំឡុងពេលវេទិកា៖**<br>• ផ្សព្វផ្សាយព័ត៌មានដែលបានអនុម័តក្នុងអង្គប្រជុំ និងរៀបចំដោយក្រុមផ្សព្វផ្សាយព័ត៌មាន<br>• កត់ត្រាបញ្ហាប្រជាពលរដ្ឋលើកឡើងក្នុងវេទិកា<br>**ក្រោយពេលវេទិកា៖**<br>• រៀបចំកំណត់ហេតុសង្ខេបអំពីលទ្ធផលរបស់វេទិកា ជាពិសេសអំពីចំនួនបញ្ហាប្រជាពលដ្ឋលើកឡើងក្នុងវេទិកា  ចំនួនបញ្ហាបានឆ្លើយតប និងចំណាត់ការរបស់ក្រុមប្រឹក្សាចំពោះបញ្ហាមិនអាចដោះស្រាយបានក្នុងវេទិកា សម្រាប់ផ្សព្វផ្សាយ<br>• ផ្សព្វផ្សាយជាសាធារណៈនូវកំណត់ហេតុសង្ខេប តាមរយៈកិច្ចប្រជុំប្រចាំខែ មេក្រុ ក្តារព័ត៌មាន បណ្តាញសហគមន៍មូលដ្ឋាន និងប្រព័ន្ធផ្សព្វផ្សាយ ។ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្តានុពលដែលក្រុមប្រឹក្សានឹងយកទៅផ្សព្វផ្សាយក្នុងវេទិកា៖<br>▪ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា<br>▪ សមិទ្ធិផលសម្រេចបានក្នុងឆ្នាំកន្លងមក<br>▪ ផែនការអភិវឌ្ឍន៍របស់ក្រុងបាត់ដំបង ជាពិសេសគម្រោងដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>▪ ថវិកាចំណាយសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំមុន និងបច្ចុប្បន្ន<br>▪ បញ្ហា ក្តីកង្វល់ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាក្រុងបានដោះស្រាយកន្លងមក<br>▪ មូលហេតុចំពោះបញ្ហាដែលក្រុមប្រឹក្សាមិនអាចដោះស្រាយបាន ។ |
| **៣) កិច្ចប្រជុំប្រចាំខែក្រុមប្រឹក្សាក្រុង** | ដើម្បីទាក់ទាញ លើកកម្ពស់ភាពអង់អាច ការចូលរួមរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន និងធានានូវការទទួលបានព័ត៌មាន  ក្រុមប្រឹក្សាក្រុង៖<br>**មុនពេលកិច្ចប្រជុំប្រចាំខែ៖**<br>• កំណត់ព័ត៌មានសម្រាប់ផ្សព្វផ្សាយក្នុងកិច្ចប្រជុំប្រចាំខែ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្តានុពល ដែលក្រុមប្រឹក្សានឹងផ្សព្វផ្សាយក្នុងពេលកិច្ចប្រជុំប្រចាំខែ ៖<br>**១) រាយការណ៍ដោយសង្ខេបអំពី៖** |

| មគោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
|---|---|---|
| | • រៀបចំរបៀបវារៈកិច្ចប្រជុំចាំខែរបស់ក្រុមប្រឹក្សាក្រុង ដោយទុកពេលវេលាគ្រប់គ្រាន់សម្រាប់៖ ១) រាយការណ៍ ២)ធ្វើការបូកសរុបចំណុចសំខាន់ៗដែលមានផលប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងការផ្សព្វផ្សាយបន្ត និង ៣) ប្រកាសព័ត៌មានអំពីប្រតិទិននៃសកម្មភាពរបស់ក្រុមប្រឹក្សាក្រុងក្នុងខែបន្ទាប់។<br><br>**ក្នុងកិច្ចប្រជុំប្រចាំខែ ៖**<br>• អនុលោមទៅតាមរបៀបវារៈដែលបានអនុម័ត ឬត្រៀមទុក។<br><br>**ក្រោយកិច្ចប្រជុំប្រចាំខែ**<br>• សង្ខេបអំពីលទ្ធផលនៃកិច្ចប្រជុំប្រចាំខែជាពិសេសអំពីចំនួនបញ្ហាប្រជាពលរដ្ឋលើកឡើងក្នុងវេទិកា ចំនួនបញ្ហាបានឆ្លើយតប និងចំណាត់ការរបស់ក្រុមប្រឹក្សាចំពោះបញ្ហាមិនអាចដោះស្រាយបានក្នុងវេទិកាសម្រាប់ផ្សព្វផ្សាយ<br>• ផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលសង្ខេបប្រជុំ តាមរយៈវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ មេក្រូ ក្តារព័ត៌មាន បណ្តាញសហគមន៍មូលដ្ឋាន និងប្រព័ន្ធផ្សព្វផ្សាយ។ | • លទ្ធផលប្រជុំខែមុន ជាពិសេសចំនួនបញ្ហាប្រជាពលរដ្ឋលើកឡើង ចំនួនបញ្ហាក្រុមប្រឹក្សាបានឆ្លើយតប និងចំនួនបញ្ហាដែលក្រុមប្រឹក្សាបានលើកយកមកពិភាក្សាដើម្បីចាត់វិធានការ<br>• ការប្រើប្រាស់ថវិកា (ចំណូល ចំណាយ)<br>• ផែនការអភិវឌ្ឍន៍របស់ក្រុង ជាពិសេសផែនការដែលប៉ះពាល់ដល់ប្រយោជន៍ប្រជាពលរដ្ឋ<br>• ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង និងចំណាត់ការ<br>**២) ការបូកសរុបឡើងវិញអំពី ៖** ចំនួនបញ្ហាប្រជាពលរដ្ឋលើកឡើង ចំនួនបញ្ហាក្រុមប្រឹក្សាបានឆ្លើយតប និងចំនួនបញ្ហាដែលក្រុមប្រឹក្សាបានលើកយកមកពិភាក្សាដើម្បីចាត់វិធានការ<br><br>**៣) ប្រកាសអំពីពេលវេលា ទីកន្លែង៖**<br>• ប្រជុំប្រចាំខែលើកក្រោយ<br>• រៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ (ប្រសិនបើមាន)<br>• ចុះសង្កេតក្រុមប្រឹក្សាសង្កាត់ចុះពិគ្រោះយោបល់នៅមូលដ្ឋានកម្មវិធីវិនិយោគ (ផែនការអភិវឌ្ឍន៍) (ប្រសិនបើមាន)<br>• ធ្វើសមាហរណកម្មកម្មវិធីវិនិយោគ (ផែនការអភិវឌ្ឍន៍)<br>• ប្រកាសពីការសម្រេចចិត្ត ឬដីការ របស់ក្រុមប្រឹក្សាដែលប៉ះ |

| មគោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
|---|---|---|
| | | ពាល់ផលប្រយោជន៍ប្រជាពលរដ្ឋ (ប្រសិនបើមាន) |
| ៤) មេក្រូ (ខ្មែរក្សាសនសំឡេ) | មេក្រូ គឺជាមធ្យោបាយមួយដែលមានភាពសាមញ្ញ និងងាយស្រួលផ្សព្វផ្សាយព័ត៌មានឱ្យដល់មូលដ្ឋានដោយផ្ទាល់ ជាពិសេសក្រុមជនងាយរងគ្រោះ ដូច្នេះដើម្បីធានាថាព័ត៌មានដែលផ្សព្វផ្សាយមានប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ ក្រុមប្រឹក្សា៖<br>**មុនពេលផ្សព្វផ្សាយ ៖**<br>• កំណត់ និងអនុម័តប្រភេទព័ត៌មានសម្រាប់យកទៅផ្សព្វផ្សាយតាមមេក្រូ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំផែនការផ្សព្វផ្សាយ និងការចំណាយសម្រាប់ការផ្សព្វផ្សាយ ដើម្បីដាក់ឱ្យក្រុមប្រឹក្សាអនុម័យ<br>• ចាត់ក្រុមផ្សព្វផ្សាយព័តមានផលិតព័ត៌មានសង្ខេប ទៅតាមការអនុម័តរបស់ក្រុមប្រឹក្សា<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានចុះផ្សព្វផ្សាយទៅតាមផែនការដែលអនុម័តរបស់ក្រុមប្រឹក្សា<br>**ក្នុងពេលផ្សព្វផ្សាយ**<br>• ចុះផ្សព្វផ្សាយទៅតាមផែនការដែលអនុម័តដោយក្រុមប្រឹក្សា<br>• ប្រមូលព័ត៌មានត្រលប់ពីប្រជាពលរដ្ឋចំពោះការផ្សព្វផ្សាយព័ត៌មានរបស់ក្រុមប្រឹក្សា<br>**ក្រោយផ្សព្វផ្សាយព័ត៌មាន**<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំរបាយការណ៍ខ្លី និងរាយការណ៍ជូនក្រុមប្រឹក្សាក្នុងកិច្ចប្រជុំប្រចាំខែ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្តានុពលដែលក្រុមប្រឹក្សានឹងផ្សព្វផ្សាយតាមរយៈមេក្រូ៖<br>▪ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំប្រចាំខែ<br>▪ ពេលវេលា និងទីកន្លែងនៃការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>▪ ពេលវេលា និងទីកន្លែងដែលក្រុមប្រឹក្សាចុះសង្កេតការពិគ្រោះយោបល់នៅមូលដ្ឋាន<br>▪ ស្ប៉ុតស្តីពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា<br>▪ សមិទ្ធិផលសម្រេចបានក្នុងឆ្នាំកន្លងមក<br>▪ ផែនការអភិវឌ្ឍន៍ក្នុងសហគមន៍<br>▪ ការប្រើប្រាស់ថវិកា (ចំណូល ចំណាយ)សម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំមុន និងបច្ចុប្បន្ន<br>▪ លទ្ធផលនៃការដោះស្រាយបញ្ហា ទាំងវិជ្ជមាន និងអវិជ្ជមាន |

| មធ្យោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
|---|---|---|
| ៥) ក្ដារព័ត៌មាន | ក្ដារព័ត៌មាន គឺជាមធ្យោបាយមួយដែលមានភាពសាមញ្ញ ចំណាយតិច និងអាចផ្សព្វផ្សាយព័ត៌មានបានច្រើនប្រភេទក្នុងពេលតែមួយ ដូច្នេះដើម្បីធានាថាព័ត៌មានដែលផ្សព្វផ្សាយមានប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ ក្រុមប្រឹក្សា៖<br>• កំណត់ប្រភេទព័ត៌មានសម្រាប់បិទផ្សាយ<br>• រៀបចំផែនការផ្លាស់ប្ដូរព័ត៌មាន និងការចំណាយថតចម្លងឯកសារសម្រាប់បិទផ្សាយ<br>• រៀបចំផលិតព័ត៌មានសង្ខេប (ខ្លឹមសារខ្លី សាមញ្ញ) ទៅតាមការអនុម័តរបស់ក្រុមប្រឹក្សា<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មាន យកព័ត៌មានតាមការអនុម័តរបស់ក្រុមប្រឹក្សាទៅបិទផ្សាយ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មាន ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានដឹង ដើម្បីទៅមើលព័ត៌មានបិទផ្សាយលើក្ដារព័ត៌មាន តាមរយៈ ការចុះសង្កេតកាពិគ្រោះយោបល់នៅមូលដ្ឋានរបស់ក្រុមប្រឹក្សាសង្កាត់ ការប្រជុំប្រចាំខែ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ មេក្រូ និងបណ្ដាញសហគមន៍មូលដ្ឋាន<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មាន ឱ្យតាមដានមើលការប្រើប្រាស់ (តើប្រជាពលរដ្ឋមើលព័ត៌មានបិទផ្សាយឬអត់) ដើម្បីផ្លាស់ប្ដូរយុទ្ធសាស្ត្រ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំរបាយការណ៍ខ្លីសម្រាប់រាយការណ៍ជូនក្រុមប្រឹក្សាក្នុងកិច្ចប្រជុំប្រចាំខែ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្ដានុពលដែលក្រុមប្រឹក្សានឹងបិទផ្សាយតាមរយៈក្ដារព័ត៌មាន៖<br>▪ ពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង<br>▪ ពេលវេលា និងទីកន្លែងនៃការរៀបចំវេទិកា<br>▪ ពេលវេលា និងទីកន្លែងដែលក្រុមប្រឹក្សាចុះសង្កេតការពិគ្រោះយោបល់នៅមូលដ្ឋាន<br>▪ លទ្ធផលសង្ខេបស្ដីពី ប្រជុំប្រចាំខែ ប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង<br>▪ កំណត់ហេតុសង្ខេបនៃ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>▪ តម្លៃសេវាសាធារណៈ<br>▪ ផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន រួមទាំងគម្រោងដែលមានផលប៉ះពាល់ដល់ផលប្រយោជន៍ប្រជាពលរដ្ឋ<br>▪ ចំណូល ចំណាយរបស់ក្រុង<br>▪ ការសម្រេចនានា និងដីការ របស់ក្រុមប្រឹក្សា<br>▪ សេចក្ដីប្រកាស ឬសេចក្ដីជូនដំណឹងផ្សេងៗរបស់ក្រុមប្រឹក្សាក្រុង |

| មធ្យោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
|---|---|---|
| ៦) បណ្ដាញសហគមន៍មូលដ្ឋាន | បណ្ដាញសហគមន៍មូលដ្ឋាន គឺជាមធ្យោបាយមួយដែលមានប្រសិទ្ធភាព ចំណាយថវិកាតិច ហើយអាចផ្សព្វផ្សាយព័ត៌មានបានដល់ប្រជាពលរដ្ឋដោយផ្ទាល់ ហេតុដូច្នេះទើបក្រុមប្រឹក្សាតែងតែ ៖<br>• កំណត់ និងអនុម័តប្រភេទព័ត៌មានសម្រាប់ចែកជូនបណ្ដាញសហគមន៍មូលដ្ឋានចូលរួមប្រជុំប្រចាំខែ និងជាសមាជិកក្រុមផ្សព្វផ្សាយព័ត៌មាន<br>• អញ្ជើញតំណាងសហគមន៍មូលដ្ឋានចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ<br>• អញ្ជើញតំណាងសហគមន៍មូលដ្ឋានចូលរួមក្នុងវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>• ចែករំលែករបាយការណ៍សង្ខេបអំពីលទ្ធផលនៃកិច្ចប្រជុំប្រចាំខែ ដល់បណ្ដាញសហគមន៍មូលដ្ឋាន យកផ្សព្វផ្សាយបន្ត<br>• ចែករំលែករបាយការណ៍សង្ខេបអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ ដល់បណ្ដាញសហគមន៍មូលដ្ឋាន យកផ្សព្វផ្សាយបន្ត ក្នុងប្រជុំប្រចាំខែ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មាន តាមដានមើលពីការផ្សព្វផ្សាយបន្តរបស់បណ្ដាញសហគមន៍មូលដ្ឋាន (តើព័ត៌មានបានដល់ប្រជាពលរដ្ឋ ឬអត់) ដើម្បីផ្លាស់ប្ដូរយុទ្ធសាស្ត្រ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំរបាយការណ៍ខ្លីសម្រាប់រាយការណ៍ជូនក្រុមប្រឹក្សាក្នុងកិច្ចប្រជុំប្រចាំខែ។ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្ដានុពលដែលក្រុមប្រឹក្សានឹងចែករំលែកដល់បណ្ដាញសហគមន៍មូលដ្ឋានដើម្បីយកទៅបិទផ្សាយបន្ត៖<br>▪ ពេលវេលា និងទីកន្លែងនៃប្រជុំប្រចាំខែ<br>▪ ពេលវេលា និងទីកន្លែងនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់<br>▪ ពេលវេលា និងទីកន្លែងនៃការចុះសង្កេតការពិគ្រោះយោបល់នៅមូលដ្ឋាន<br>▪ លទ្ធផលសង្ខេបស្ដីពីការប្រជុំប្រចាំខែ ឬប្រជុំវិសាមញ្ញដែលទាក់ទងនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>▪ កំណត់ហេតុសង្ខេបស្ដីពី លទ្ធផលនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>▪ តារាងតម្លៃសេវាសាធារណៈ<br>▪ ផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន រួមទាំងផែនការអភិវឌ្ឍន៍ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>▪ ចំណូល ចំណាយរបស់ក្រុង<br>▪ ការសម្រេច និងដីការ របស់ក្រុមប្រឹក្សា<br>▪ សេចក្ដីប្រកាស ឬសេចក្ដីជូនដំណឹងផ្សេងៗ ។ |

| មធ្យោបាយជាយុទ្ធសាស្ត្រ | សកម្មភាពអនុវត្ត | ប្រភេទព័ត៌មានត្រូវផ្សព្វផ្សាយ |
|---|---|---|
| ៧) ប្រព័ន្ធផ្សព្វផ្សាយ | ប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានក្រុមប្រឹក្សាមើលឃើញថា ជាមធ្យោបាយបញ្ជូនព័ត៌មានដ៏មានប្រសិទ្ធភាព បានលឿន ទាន់ពេលវេលា និងបានទូលំទូលាយទូទាំងប្រទេស ហេតុដូច្នេះទើបក្រុមប្រឹក្សា៖<br>• កំណត់ប្រភេទព័ត៌មានសម្រាប់ផ្សព្វផ្សាយតាមបណ្ដាញប្រព័ន្ធផ្សព្វផ្សាយ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានផលិតព័ត៌មានសម្រាប់ចែករំលែកដល់ក្រុមអ្នកសារព័ត៌មាន<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានរៀបចំលិខិត ដើម្បីអញ្ជើញ និងជូនដំណឹងដល់ប្រព័ន្ធផ្សព្វផ្សាយ ឱ្យចូលរួមយកព័ត៌មានក្នុង៖<br>o កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង<br>o វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>o សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគក្រុង<br>o វគ្គបណ្ដុះបណ្ដាល ឬព្រឹត្តិការណ៍ផ្សេងៗរបស់ក្រុមប្រឹក្សា ។ល។<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានឱ្យតាមដានការផ្សព្វផ្សាយបន្តរបស់ប្រព័ន្ធផ្សព្វផ្សាយ និងប្រមូលចងក្រងទុកជាឯកសារ<br>• ចាត់ក្រុមផ្សព្វផ្សាយព័ត៌មានឱ្យរៀបចំរបាយការណ៍ខ្លីសម្រាប់រាយការណ៍ជូនក្រុមប្រឹក្សាក្នុងកិច្ចប្រជុំប្រចាំខែ | ខាងក្រោម គឺជាប្រភេទព័ត៌មានសក្ដានុពលដែលក្រុមប្រឹក្សានឹងចែករំលែកដល់ប្រព័ន្ធផ្សព្វផ្សាយដើម្បីយកទៅផ្សព្វផ្សាយបន្ត៖<br>▪ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា<br>• សមិទ្ធផលសម្រេចបានក្នុងឆ្នាំកន្លងមករបស់ក្រុមប្រឹក្សាក្រុង<br>• ការប្រើប្រាស់ថវិកា (ចំណូល ចំណាយ)សម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំមុន និងបច្ចុប្បន្ន<br>• លទ្ធផលនៃការដោះស្រាយបញ្ហា ទាំងវិជ្ជមាន និងអវិជ្ជមាន<br>• លទ្ធផលនៃការប្រជុំប្រចាំខែ ឬប្រជុំវិសាមញ្ញដែលទាក់ទងនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>• លទ្ធផលនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់<br>• តារាងតម្លៃសេវាសាធារណៈ<br>• ផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន រួមទាំងផែនការអភិវឌ្ឍន៍ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ<br>• ការសម្រេច និងដីការ របស់ក្រុមប្រឹក្សា<br>• សេចក្ដីប្រកាស ឬសេចក្ដីជូនដំណឹងផ្សេងៗ |

## ឧបសម្ព័ន្ធ "ខ"÷ សេចក្តីរៀបរាប់លំអិតអំពីមាត្រានានានៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពីការផ្សព្វផ្សាយព័ត៌មាន

**មាត្រា៣៦:** រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តី ឬដីការតាមការចាំបាច់ដែលទាក់ទិនទៅនឹង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- កម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាពនៃផែនការនោះ ដែលស្ថិតនៅក្រោមនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមផ្គា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យម
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការអង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- <u>ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ</u>
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់ ។

**មាត្រា៤១:** ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ នូវផែនការអភិវឌ្ឍន៍បន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។ សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬអាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សាដោយគិតត្រឹមតម្លៃដើម ។

**មាត្រា៥១ :** ក្រុមប្រឹក្សាត្រូវបង្កលក្ខណៈងាយស្រួលដល់សាធារជនក្នុងការជូនព័ត៌មានជាសាធារណៈ នូវរបាយការណ៍ របៀបវារៈប្រជុំ កំណត់ហេតុប្រជុំ ដីកា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងអស់ ដែលពាក់ព័ន្ធនឹងក្រុមប្រឹក្សា និងឯកសារដទៃទៀតរបស់ក្រុមប្រឹក្សា។

**មាត្រា៥២:** ក្រុមប្រឹក្សានីមួយៗ ត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ។

**មាត្រា៧៦:** ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវប្រតិទិននៃការប្រជុំសាមញ្ញរបស់ខ្លួន។

**មាត្រា១៦៩:** គណៈអភិបាលត្រូវធានាឱ្យមានក្តារបិទផ្សាយព័ត៌មាន និងមធ្យោបាយផ្សព្វផ្សាយព័ត៌មាន ផ្សេងៗទៀត តាមតម្រូវការរបស់ក្រុមប្រឹក្សារបស់ខ្លួន ។ រាល់ឯកសារទាំងអស់ដែលបានបោះពុម្ពផ្សាយស្របតាមច្បាប់នេះ ត្រូវតែបិទផ្សាយនៅលើក្តារព័ត៌មាន ឬត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

**មាត្រា១៧០ :** គណៈអភិបាលត្រូវធានាឱ្យសាធារណជន មានលទ្ធភាពគ្រប់គ្រាន់ក្នុងការពិនិត្យមើលព័ត៌មាននានា នៅលើក្តារបិទផ្សាយព័ត៌មាន ហើយត្រូវធានាថែរក្សាការពារសុវត្ថិភាពក្តារព័ត៌មាន ដែលមានក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

## ឧបសម្ព័ន្ធ "គ"÷ សេចក្តីសម្រេច និងលក្ខខណ្ឌការងាររបស់ក្រុមការងារផ្សព្វផ្សាយព័ត៌មាន

ក្រុមប្រឹក្សាក្រុងបាត់ដំបង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបាត់ដំបង
សាលាក្រុងបាត់ដំបង
លេខ:០២ សសរ/ក្រស

**សេចក្តីសម្រេច**
**ស្តីពីការបង្កើត**
**ក្រុមផ្សព្វផ្សាយព័ត៌មាន ក្រុងបាត់ដំបង**

**ប្រធានក្រុមប្រឹក្សាក្រុងបាត់ដំបង**

- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ៩៨៧ អនក្រ. តត ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុង បាត់ដំបង
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោង អនុស្សរណៈនៃការយោគយល់គ្នា ស្តីពី "ការសហការ និងគាំទ្រអនុវត្តគម្រោង លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ក្រុង/ស្រុក នៃខេត្តបាត់ដំបង " រវាងអង្គការអមរា ជាមួយនឹងរដ្ឋបាលក្រុងបាត់ដំបង
- យោង ការអនុម័តបង្កើតក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបងក្នុងកិច្ចប្រជុំសាមញ្ញលើកទី ៥០ របស់ក្រុមប្រឹក្សាក្រុងបាត់ដំបងកាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣ ។

**សម្រេច**

**ប្រការ ១ :**

បង្កើត ក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១- | លោក | **ទេព ប៊ុនទ** | សមាជិកក្រុមប្រឹក្សាក្រុង | ជាប្រធាន |
| ២- | លោក | **ប៉ែន សារិយា** | អភិបាលរងក្រុង | ជាអនុប្រធាន |
| ៣- | លោក | **សៀ បេន** | សមាជិកក្រុមប្រឹក្សាក្រុង | ជាសមាជិក |
| ៤- | លោក | **មៀច គន** | សមាជិកក្រុមប្រឹក្សាក្រុង | ជាសមាជិក |
| ៥- | លោក | **ថោង ទី** | ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | ជាសមាជិកអចិន្ត្រៃយ៍ |

| | | | | |
|---|---|---|---|---|
| ៦- | លោក | **ឯម វិរិទ្ធ** | ប្រធានការិយាល័យប្រជាពលរដ្ឋ | ជាសមាជិក |
| ៧- | លោក | **អ៊ុក គីម** | តំណាងក្រុមប្រឹក្សាសង្កាត់ | ជាសមាជិក |
| ៨- | លោក | **ទី សុខុនសក្តិ** | មន្ត្រីមន្ទីរព័ត៌មាន ខេត្ត | ជាសមាជិក |
| ៩- | លោក | **លន់ ម៉ាប់** | តំណាងសហគមន៍មូលដ្ឋាន | ជាសមាជិក |
| ១០- | លោក | **សួន សាមីឌី** | មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | ជាលេខាធិការ |

**ប្រការ ២ :**

ក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង មានភារកិច្ច :

- រៀបចំផែនការសកម្មភាព ឱ្យបានត្រឹមត្រូវ ច្បាស់លាស់
- ផ្សព្វផ្សាយព័ត៌មាន ដល់ប្រជាពលរដ្ឋ ក្នុងក្រុងបាត់ដំបង និងប្រមូលព័ត៌មានត្រឡប់មកវិញ ឱ្យកាន់តែមានប្រសិទ្ធភាព ដូចមានចែងក្នុងមាត្រា ៣៦ ,៤១, ៥១, ៥២, ៧៦, ១៦៩, ១៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សហការល្អ ជាមួយអង្គការ អមរា តាមស្មារតីអនុស្សរណៈនៃការយោគយល់គ្នា
- ប្រជុំប្រចាំខែ បូកសរុបលទ្ធផលនៃការផ្សព្វផ្សាយ ប្រមូលព័ត៌មាន និងរាយការណ៍ជូន ក្រុមប្រឹក្សា នៅរៀងរាល់កិច្ចប្រជុំសាមញ្ញ របស់ក្រុមប្រឹក្សា
- ការិយាល័យបំពេញការងារ របស់ក្រុមផ្សព្វផ្សាយព័ត៌មាននេះ ស្ថិតនៅក្រោមការរៀបចំរបស់ គណៈអភិបាលក្រុង ។

**ប្រការ ៣ :**

ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងអស់លោក ដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្ត សេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

បាត់ដំបង, ថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០១៣

**ប្រធានក្រុមប្រឹក្សាក្រុង**

**ចម្លងជូន :**

- ក្រសួងមហាផ្ទៃ
- សាលាខេត្តបាត់ដំបង

" ដើម្បីគោរពជូនជ្រាប "

- ដូចប្រការ១ និងប្រការ ៣
- សង្កាត់ទាំង ១០ ក្នុងក្រុង

" ដើម្បីអនុវត្ត "

- ឯកសារ - កាលប្បវត្តិ

ការផ្សព្វផ្សាយព័ត៌មានរបស់ក្រុមប្រឹក្សាក្រុង ជាយន្តការមួយ ដ៏មានប្រសិទ្ធភាពក្នុងការធ្វើឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានដឹងពីស្ថានភាព និងលទ្ធផលនៃការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន ព្រមទាំងស្ថានភាពថវិកា ហិរញ្ញវត្ថុ រួមមានចំណូល ចំណាយប្រកបដោយតម្លាភាព ។

ការផ្សព្វផ្សាយព័ត៌មាន គឺជាមធ្យោបាយមួយសម្រាប់កៀងគរប្រជាពលរដ្ឋឱ្យចូលរួមគ្រប់សកម្មភាពរបស់ក្រុមប្រឹក្សា និងប្រើប្រាស់នូវសេវាផ្សេងៗដែលក្រុមប្រឹក្សាក្រុងបានផ្តល់ ព្រមទាំងផ្តល់ឱកាសឱ្យសហគមន៍មូលដ្ឋាន មានលទ្ធភាពក្នុងការផ្តល់ព័ត៌មាន ពាក់ព័ន្ធនឹងគុណភាពនៃសេវាដែលរដ្ឋបាលក្រុងបានផ្តល់ ត្រឡប់មកជូនក្រុមប្រឹក្សាវិញ ។

## ២. គោលបំណង នៃការបង្កើតក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង :

គោលបំណងនៃការបង្កើតក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង គឺដើម្បីផ្សព្វផ្សាយនូវរាល់ព័ត៌មានដែលទាក់ទងនឹងសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង ដំណើរការអភិវឌ្ឍមូលដ្ឋាន និងលទ្ធផលនានាដែលរដ្ឋបាលក្រុងសម្រេចបាន មានដូចជា ផែនការអភិវឌ្ឍ កម្មវិធីវិនិយោគពាឆ្នាំរំកិល ផែនការហិរញ្ញវត្ថុ ថវិកាចំណូលចំណាយ ប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង លិខិតបទដ្ឋានគតិយុត្តិនានាដែលចេញដោយក្រុមប្រឹក្សាក្រុងមានដូចជា ដីកា សេចក្តីសម្រេច ចំណាត់តាំងនានា ជាដើម ។

## ៣. សមាសភាព នៃក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង :

សមាសភាព ក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង រួមមាន :

| | |
|---|---|
| ❖ សមាជិកក្រុមក្រុង ០១ រូប | ជា ប្រធាន |
| ❖ សមាជិកក្រុមប្រឹក្សាក្រុង ០២ រូបផ្សេងទៀត | ជា សមាជិក |
| ❖ អភិបាលរងក្រុង ០១ រូប | ជាអនុប្រធាន |
| ❖ នាយករដ្ឋបាលក្រុង ០១ រូប | ជាសមាជិកអចិន្ត្រៃយ៍ |
| ❖ ប្រធានការិយាល័យប្រជាពលរដ្ឋ០១ រូប | ជាសមាជិក |
| ❖ តំណាងក្រុមប្រឹក្សាសង្កាត់ ០១រូប | ជាសមាជិក |
| ❖ តំណាងមន្ទីរព័ត៌មានខេត្ត ០១ រូប | ជាសមាជិក |
| ❖ តំណាងសហគមន៍មូលដ្ឋាន ០១ រូប | ជាសមាជិក |
| ❖ មន្ត្រីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង០១ រូប | ជាលេខាធិការ |

## ៤. តួនាទី ភារកិច្ចរបស់ក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង :

៤.១- ប្រធានក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង មានភារកិច្ច :

- កសាងផែនការសកម្មភាព ឱ្យបានទៀងទាត់ ត្រឹមត្រូវ និងច្បាស់លាស់ ꩜

- ដឹកនាំ និងគ្រប់គ្រងក្រុមផ្សព្វផ្សាយព័ត៌មាន
- ផ្តល់ព័ត៌មានទាំងឡាយដែលកំណត់ដោយក្របខណ្ឌការងារ ដល់សមាជិកក្រុម ដើម្បីឱ្យជួយផ្សព្វផ្សាយបន្តទៅដល់ប្រជាពលរដ្ឋ
- រាយការណ៍អំពីស្ថានភាពនៃការផ្សព្វផ្សាយព័ត៌មាន ជូនក្រុមប្រឹក្សាក្នុងរាល់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង
- រៀបចំ កិច្ចសន្យាជាមួយអ្នកផ្តល់សេវាផ្សព្វផ្សាយព័ត៌មាន
- រៀបចំគម្រោងថវិកាសម្រាប់គាំទ្រដល់ចំណាយផ្សេងៗ មានការថតចម្លងឯកសារព័ត៌មាន ការបោះពុម្ពសម្ភារៈសម្រាប់យកទៅផ្សព្វផ្សាយ និងអប់រំដល់ប្រជាពលរដ្ឋ អំពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្រុង ។
- រៀបចំប្រជុំ ក្រុមផ្សព្វផ្សាយព័ត៌មាន ឱ្យបានទៀងទាត់ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃការផ្សព្វផ្សាយ និងធ្វើការបូកសរុបលទ្ធផលនៃការផ្សព្វផ្សាយដើម្បីរាយការណ៍ ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង

៤.២- សមាជិកក្រុមផ្សព្វផ្សាយព័ត៌មានក្រុងបាត់ដំបង មានភារកិច្ច :

- ពាំនាំព័ត៌មានពីប្រធានក្រុម និងក្រុមប្រឹក្សាក្រុង យកទៅផ្សព្វផ្សាយជូនប្រជាពលរដ្ឋឱ្យបានទៀងទាត់
- ផ្តល់យោបល់គ្រឡប់ និងរាយការណ៍អំពីមតិយោបល់របស់ប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងការផ្សព្វផ្សាយព័ត៌មាន
- ចូលរួមក្នុងកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុម

## ៥. ប្រភេទ និងមធ្យោបាយផ្សព្វផ្សាយព័ត៌មាន :

### ៥.១. ប្រភេទព័ត៌មានដែលត្រូវផ្សព្វផ្សាយ :

- របៀបវារៈ និងកាលបរិច្ឆេទជាក់លាក់នៃកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង
- របៀបវារៈ និងកាលបរិច្ឆេទជាក់លាក់នៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ព្រមទាំងកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា បើសិនជាមានពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋ
- សង្ខេបលទ្ធផលនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សាក្រុង បើមានទាក់ទងនឹងការសម្រេចនានារបស់ក្រុមប្រឹក្សាក្រុងដែលអាចមានឥទ្ធិពល ឬផលប៉ះពាល់ដល់ផល

ប្រយោជន៍របស់ប្រជាពលរដ្ឋ

- តួនាទី ភារកិច្ច ការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្រុង
- គម្រោងអភិវឌ្ឍនានាក្នុងមូលដ្ឋាន មានដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ថ្នល់ ទំនប់ ប្រឡាយ ប្រព័ន្ធលូ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព ជាដើម
- គម្រោងអភិវឌ្ឍដែលកំពុងអនុវត្ត ឬសម្រេចដាក់ចូលក្នុងកម្មវិធីវិនិយោគ របស់សង្កាត់
- គម្រោងថវិកា ( ចំណូល ចំណាយ ) របស់រដ្ឋបាលក្រុង និងសង្កាត់
- តម្លៃសេវារដ្ឋបាលរបស់រដ្ឋបាលក្រុង និងរដ្ឋបាលសង្កាត់
- សន្តិសុខ សុវត្ថិភាព សុខភាព អប់រំទឹកស្អាត និងអនាម័យទូទៅរបស់ប្រជាពលរដ្ឋ
- ។ល។

## ៥.២. មធ្យោបាយសម្រាប់ផ្សព្វផ្សាយព័ត៌មាន :

សមាជិកក្រុមផ្សព្វផ្សាយព័ត៌មាន គឺជាភ្នាក់ងារ ដែលធានាថាព័ត៌មានផ្សេងៗ ពាក់ព័ន្ធនឹងសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង ត្រូវបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ តាមរយៈ សារព័ត៌មាន ព្រឹត្តិបត្រ គេហទំព័រ វិទ្យុ ទូរទស្សន៍ ក្តារព័ត៌មាន មេក្រូ ការចុះសាកសួរពិគ្រោះយោបល់នៅមូលដ្ឋាន វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ បណ្តាញអង្គការសហគមន៍មូលដ្ឋាននានា ។ល។ ៛

# អនុស្សរណៈនៃការយោគយល់គ្នា

ស្តីពី

## កិច្ចសហការផ្សព្វផ្សាយព័ត៌មាន

អំពី

សកម្មភាពអភិវឌ្ឍ និងលទ្ធផលនានាដែលក្រុមប្រឹក្សាសម្រេចបាន
ក្នុងដំណើរការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
ក្រុងបាត់ដំបង ខេត្តបាត់ដំបង

( ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ - ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ )

រវាង

## រដ្ឋបាលក្រុងបាត់ដំបង

និង

## មន្ទីរព័ត៌មាន ខេត្តបាត់ដំបង

គាំទ្រមូលនិធិដោយ : ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ដើម្បីអភិវឌ្ឍ
របស់ប្រទេស ស៊ុយអែត (Sida)

## ថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១៣

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , មាត្រា ៥២ បានចែងថា ក្រុមប្រឹក្សានីមួយៗ ត្រូវមានក្តារព័ត៌មានជាសាធារណៈ ឬមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀត នៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមទីកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមការចាំបាច់ ហើយទីកន្លែងទាំងនោះមានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។

ការផ្សព្វផ្សាយព័ត៌មានរបស់ក្រុមប្រឹក្សាក្រុង ជាយន្តការមួយដ៏មានប្រសិទ្ធភាពដើម្បីឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន បានដឹងពីស្ថានភាព និងលទ្ធផលនៃការអភិវឌ្ឍរបស់មូលដ្ឋាន និងបង្ហាញពីតម្លាភាពនៃចំណូល ចំណាយរបស់រដ្ឋបាលមូលដ្ឋាន ។

ការផ្សព្វផ្សាយព័ត៌មាន គឺជាមធ្យោបាយក្នុងការកៀងគរប្រជាពលរដ្ឋឱ្យចូលរួម ក្នុងសកម្មភាពរបស់ក្រុមប្រឹក្សា និងប្រើប្រាស់សេវាដែលរដ្ឋបាលក្រុងបានផ្តល់ព្រមទាំងសហគមន៍មូលដ្ឋានមានលទ្ធភាពក្នុងការផ្តល់ព័ត៌មានត្រឡប់ មកក្រុមប្រឹក្សាក្រុង អំពីគុណភាពនៃសេវាដែលបានទទួល ។

ក្រុមប្រឹក្សាក្រុងបាត់ដំបង នៃខេត្តបាត់ដំបង និងមន្ទីរព័ត៌មានខេត្តបាត់ដំបង បានប្តេជ្ញាចិត្តលើកកម្ពស់សិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ ការផ្សព្វផ្សាយព័ត៌មានបានទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព តម្លាភាព ដល់សាធារណជន ព្រមទាំងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពរបស់ក្រុមប្រឹក្សាក្រុងបាត់ដំបងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ វិទ្យុ និងទូរទស្សន៍នានា ដែលស្ថិតនៅក្រោមឱវាទ របស់មន្ទីរព័ត៌មានខេត្តបាត់ដំបង ។

ដើម្បីឱ្យការផ្សព្វផ្សាយព័ត៌មាន អំពី " **សកម្មភាពអភិវឌ្ឍ និងលទ្ធផលនានាដែលក្រុមប្រឹក្សាសម្រេចបាន ក្នុងដំណើរការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** " បានទូលំទូលាយ ដល់សាធារណជន ក្រុមប្រឹក្សាក្រុងបាត់ដំបង និងមន្ទីរព័ត៌មានខេត្តបាត់ដំបង បានប្តេជ្ញាចិត្តដូចខាងក្រោម :

**១. ភាគីមន្ទីរព័ត៌មាន ខេត្តបាត់ដំបង :**

ក- កិច្ចសហការ និងការប្តេជ្ញាចិត្ត :

- ចូលរួមដើម្បីយកព័ត៌មានជាប្រចាំ នូវរាល់សកម្មភាពអភិវឌ្ឍ របស់ក្រុមប្រឹក្សាក្រុងបាត់ដំបង
- សហការ និងចាត់មន្ត្រី ភ្នាក់ងារ ក្រុមអ្នកយក ឬផលិតព័ត៌មាននៃមន្ទីរព័ត៌មានខេត្តបាត់ដំបងឬតំណាងស្ថានីយ៍វិទ្យុ និងទូរទស្សន៍នានាដើម្បីចូលរួមផលិត និងផ្សព្វផ្សាយសកម្មភាពអភិវឌ្ឍ និងលទ្ធផលនានា ដែលក្រុមប្រឹក្សាក្រុងបាត់ដំបង សម្រេចបានក្នុងដំណើរការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឱ្យបានទូលំទូលាយ ដល់ប្រជាពលរដ្ឋក្នុងក្រុងបាត់ដំបងទាំងមូល
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល ជាមួយក្រុមប្រឹក្សាក្រុង ពាក់ព័ន្ធនឹងការងារអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ខ- ប្រភេទព័ត៌មានដែលត្រូវផ្សព្វផ្សាយ រួមមាន :

- របៀបវារៈ និងកាលបរិច្ឆេទនៃកិច្ចប្រជុំប្រចាំខែ និងកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាសង្កាត់
- កាលបរិច្ឆេទ និងប្រធានបទនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង និងរបស់ក្រុមប្រឹក្សាសង្កាត់ លទ្ធផលសង្ខេបនៃកិច្ចប្រជុំសាមញ្ញប្រចាំខែ និងកិច្ចប្រជុំនានា របស់ក្រុមប្រឹក្សា ទាក់ទងនឹងការសម្រេចចិត្ត ដែលមានផលប្រយោជន៍ដល់ប្រជាពលរដ្ឋ
- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាក្រុង
- គម្រោងអភិវឌ្ឍនានា ក្នុងមូលដ្ឋាន
- ប្រកាសជូនដំណឹងអំពីគម្រោងអភិវឌ្ឍ ដែលអនុម័ត ឬសម្រេចដាក់ចូលក្នុងកម្មវិធីវិនិយោគ របស់សង្កាត់
- គម្រោងថវិកា និងផែនការចំណូល ចំណាយ របស់រដ្ឋបាលក្រុង សង្កាត់
- តារាងតម្លៃសេវារដ្ឋបាលរបស់រដ្ឋបាលក្រុង និងរដ្ឋបាលសង្កាត់ ដែលរាជរដ្ឋាភិបាលបាន កំណត់
- សន្តិសុខ សុវត្ថិភាព សុខភាព អប់រំអំពីទឹកស្អាត និងអនាម័យ របស់ប្រជាពលរដ្ឋ
- ព័ត៌មានទាក់ទងនឹងផលប្រយោជន៍ និងតម្រូវការរបស់ក្រុមជនងាយរងគ្រោះ
- ចំណោត់ការ និងដំណោះស្រាយ

គ- មធ្យោបាយផ្សព្វផ្សាយព័ត៌មាន :

មន្ទីរព័ត៌មានខេត្តបាត់ដំបង គឺជាភ្នាក់ងារធានាការផ្សព្វផ្សាយព័ត៌មាន ដល់ប្រជាពលរដ្ឋអំពីសកម្មភាពអភិវឌ្ឍ និង លទ្ធផលនានា ដែលក្រុមប្រឹក្សាក្រុងបាត់ដំបងសម្រេចបាន ក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈវិទ្យុ និងទូរទស្សន៍នានា ឬតាមមធ្យោបាយផ្សេងៗទៀត ក្នុងការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន ប្រកបដោយតម្លាភាពរបស់ប្រជាពលរដ្ឋ និងបង្កើនការចូលរួម និងចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋ លើអភិបាលកិច្ចល្អ នៅថ្នាក់ក្រុង និងសង្កាត់ ។

**២. ភាគីរដ្ឋបាលក្រុង :**

- ការប្ដេជ្ញាចិត្តរបស់ក្រុមប្រឹក្សាក្រុងបាត់ដំបង :

ដើម្បីបង្កលក្ខណៈងាយស្រួលដល់មន្ត្រី អ្នកសារព័ត៌មាន ភ្នាក់ងារឬក្រុមអ្នកយក និងផលិតព័ត៌មាន ដើម្បីយកទៅផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុ និងទូរទស្សន៍បានឆាប់រហ័ស និងទាន់ពេលវេលា ក្រុមប្រឹក្សាក្រុងបាត់ដំបង នៃខេត្តបាត់ដំបង ធានាសហការ និងផ្ដល់ជូននូវមន្ត្រីទទួលទទួលបន្ទុកព័ត៌មាន ដូចតទៅ :

- ចាត់តាំងឱ្យមានមន្ត្រីទទួលបន្ទុកព័ត៌មាន ០១ រូប ឬច្រើនរូបដើម្បីសហការ និងផ្ដល់នូវព័ត៌មានជូនភ្នាក់ងារ អ្នកយកព័ត៌មានដែលស្ថិតនៅក្រោមឱវាទរបស់មន្ទីរព័ត៌មានខេត្ត

- ផ្តល់ព័ត៌មានជាមុន ឬជាប្រចាំ អំពីសកម្មភាពអភិវឌ្ឍរបស់ខ្លួន ដល់អ្នកសារព័ត៌មានដើម្បី បង្កលក្ខណៈឱ្យអ្នកសារព័ត៌មាន ទទួលបាននូវព័ត៌មានច្បាស់លាស់ និងទាន់ពេលវេលា
- រាល់សកម្មភាពបណ្តុះបណ្តាល ដែលរៀបចំដោយរដ្ឋបាលក្រុង សហការជាមួយអង្គការមិន មែនរដ្ឋាភិបាលនានា ត្រូវអញ្ជើញអ្នកសារព័ត៌មាន ឱ្យចូលរួម និងយកព័ត៌មាន ដើម្បីផ្សព្វ ផ្សាយដល់សាធារណជន ។
- ផ្តល់ព័ត៌មានបច្ចុប្បន្នភាពជូនដល់អ្នកសារព័ត៌មាន ជាប្រចាំស្តីពីគម្រោងលើកកម្ពស់ការចូល រួមរបស់ប្រជាពលរដ្ឋក្នុង ដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## ៣. ភារកិច្ច សមាគម

- ដើម្បីជាការរួមចំណែកក្នុងការពង្រឹង និងលើកកម្ពស់សិទ្ធិទទួលបាននូវព័ត៌មានប្រកបដោយ ប្រសិទ្ធភាព និងតម្លាភាព របស់ប្រជាពលរដ្ឋ រដ្ឋបាលក្រុងបាត់ដំបងទទួលរ៉ាប់រងការចំណាយ សម្រាប់ការធ្វើដំណើរ ចុះទៅបំពេញបេសកកម្មផលិតព័ត៌មាន អំពីព្រឹត្តិការណ៍នានាពាក់ព័ន្ធ នឹងសកម្មភាពរបស់ក្រុមប្រឹក្សាក្រុងបាត់ដំបង ទៅតាមលទ្ធភាពដែលរដ្ឋបាលក្រុងមាន ។
- សហការជាមួយអង្គការអមរា ជាដៃគូ ក្នុងការផ្សព្វផ្សាយពីសកម្មភាពរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាសង្កាត់ និងសហគមន៍មូលដ្ឋាន ។
- ផ្តល់ជូននូវព័ត៌មាន ដែលបានចាក់ផ្សាយរួច ជូនដល់អង្គការអមរា ដើម្បីរក្សាទុកជាឯកសារ

## ៤. ការកែប្រែប្រការណាមួយ នៃអនុស្សរណៈនៃការយោគយល់គ្នា

- ភាគីណាមួយដែលមិនយល់ស្រប ឬមិនអាចអនុវត្តបាន តាមប្រការណាមួយនៃ "អនុស្សរណៈ នៃការយោគយល់គ្នា "នេះ អាចស្នើសុំឱ្យធ្វើការកែសម្រួលឡើងវិញ នូវចំណុចឬប្រការនោះ
- ភាគីទាំងពីរបានព្រមព្រៀងគ្នា ចុះហត្ថលេខាលើ "អនុស្សរណៈនៃការយោគយល់គ្នា " ចាប់ពី ពេលនេះតទៅ ។
- "អនុស្សរណៈនៃការយោគយល់គ្នា " នេះបានធ្វើឡើងជាភាសាខ្មែរ ចំនួន ពីរច្បាប់ :
  - មួយច្បាប់ តម្កល់ទុកនៅរដ្ឋបាលក្រុងបាត់ដំបង
  - មួយច្បាប់ តម្កល់ទុកនៅមន្ទីរព័ត៌មានខេត្តបាត់ដំបង ។

| | |
|---|---|
| ភាគីរដ្ឋបាលក្រុង | ភាគីមន្ទីរព័ត៌មានខេត្ត |
| ចែន ចាប់ | ............ |
| ប្រធានក្រុមប្រឹក្សាក្រុង | |


ផ្សារធំបាត់ដំបង
សាលាក្រុងបាត់ដំបង


អបអរសាទរ
ខួបលើកទី ១០៣ ទិវា អន្តរជាតិនារី ៨ មីនា ២០១៤
០៧.៣.២០១៤